# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមហ៊ុនផលិតកាបូបហាធ័រ អ៊ិនធើណេសិនណល (ខេមបូឌា) ឯ.ក

## កិច្ចព្រមព្រៀងស្នើសុំព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងស្នើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ២០៧នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ៩៦៥ នាក់ (ប្រុស ១៥៩នាក់) រយៈពេល ០១ខែ គិតចាប់ពីថ្ងៃទី ០១ខែ កញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ខែ កញ្ញា ឆ្នាំ២០២០ត្រូវបានធ្វើឡើងរវាងកម្មករនិយោជិត នឹងនិយោជកនៃក្រុមហ៊ុនផលិតកាបូបហាធ័រ អ៊ិនធើណេសិនណល (ខេមបូឌា) ឯ.ក ដោយមានការឯកភាពពីប្រតិភូបុគ្គលិកពេញសិទ្ធទាំងអស់ យល់ព្រមអោយកម្មករនិយោជិតស្នើសុំព្យួរកិច្ចសន្យាការងារ រយៈពេល ០១ខែ តាមសំណូមពររបស់ក្រុមហ៊ុនដោយគ្មានការបង្ខិតបង្ខំ។

សំរាប់រោងចក្រៈ ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារក្រុមហ៊ុនបានផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន ៣០$ ដុល្លាអាមេរិចក្នុង ០១ខែ ក្នុងនោះៈ

- ចំនួន១០$ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ០៧ថ្ងៃ ដល់ ១០ ថ្ងៃ
- ចំនួន២០$ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ ថ្ងៃ
- ចំនួន៣០$ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ០១ ខែ

**បញ្ជាក់** ៖ ប្រាក់ព្យួរកិច្ចសន្យាការងារក្រុមហ៊ុននិងបើកជូនកម្មករនិយោជិតនៅខែបន្ទាប់ថ្ងៃទី១០។

សំរាប់ប្រាក់ឧត្ថម្ភពីរាជរដ្ឋាភិបាលតាមរយៈភ្នាក់ងាររើង ដូចខាងក្រោមៈ

- ចំនួន ១៥$ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ០៧ថ្ងៃ ដល់ ១០ថ្ងៃ
- ចំនួន ៣០$ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ចំនួន ៤០$ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ០១ខែ

ក្រោយពីព្យួរកិច្ចសន្យាការងាររយៈពេល១០ ថ្ងៃ។

ដើម្បីជាភស្តុតាងលើលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ រយៈពេល០១ខែ ដែលចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០២០ យើងខ្ញុំទាំងអស់គ្នា ជាប្រតិភូបុគ្គលិកពេញសិទ្ធ ទាំងអស់សូមផ្តិតមេដៃ ដូចខាងក្រោមនេះ ៖

**តំណាងភាគីប្រតិភូបុគ្គលិកប្រចាំរោងចក្រ**

១. មិត្ត វណ្ណៈ

២. ធិន ស្រីអែម

៣. សុខ វី

៣. ទៀវ ចន្ថន

**តំណាងភាគីក្រុមហ៊ុន**

តាកែវថ្ងៃ ទី ២៦ ខែ សីហា ឆ្នាំ ២០២០

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុនផលិតកាបូបហាធ័រ អ៊ិនធើណេសិនណល (ខេមបូឌា)
人事部
HATHOR INTERNATIONAL (CAMBODIA) CO., LTD.